**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ :.................៣៥៣...........ក.ប/អ.ក.ន.ល.ក.ទ.វ

# លិខិតអំពាវនាវ

ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣១ **ទិវាពលកម្មអន្តរជាតិ ១ ឧសភា** និងដើម្បីបង្កើតបរិយាកាសសប្បាយរីករាយជូនបងប្អូនកម្មករ-កម្មការិនី ដែលកំពុងបម្រើការងារក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរ សម្លៀកបំពាក់ និងផលិតស្បែកជើង និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមសហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា សហភាពសហព័ន្ធយុវជនកម្ពុជា និងស្ថានីយទូរទស្សន៍អ៊ីធីវី រៀបចំ **កម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៧** (លើកទី៣) នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧។

កម្មវិធីនេះប្រព្រឹត្តទៅដូចខាងក្រោម៖

១.វគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ ៖ **ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧** នៅ៖

- **មណ្ឌលរាជធានីភ្នំពេញ៖** ជ្រើសរើសយកបេក្ខជន០៤រូប បេក្ខនារី០៤រូប
- **មណ្ឌលខេត្តព្រះសីហនុ៖** ជ្រើសរើសយកបេក្ខជន០៤រូប បេក្ខនារី០៤រូប
- **មណ្ឌលខេត្តស្វាយរៀង៖** ជ្រើសរើសយកបេក្ខជន០៤រូប បេក្ខនារី០៤រូប

២.កម្មវិធីប្រឡងផ្តាច់ព្រ័ត្រ៖ **ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧** វេលាម៉ោង **១៧:០០នាទី** នៅស្ថានីយទូរទស្សន៍អ៊ីធីវី (ផ្សាយផ្ទាល់) ក្នុងស្ទីដយ៉ូស្ទឹងមានជ័យ។

ដើម្បីលើកទឹកចិត្តដល់បងប្អូនកម្មករ-កម្មការិនី ជាបេក្ខជនរបស់យើង និងដើម្បីឱ្យកម្មវិធីនេះមានភាពអធិកអធម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមអំពាវនាវដល់ **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា** ជាពិសេសប្រធានរោងចក្រ សហគ្រាស មេត្តាចូលរួមទស្សនា និងគាំទ្រជាវិភាគទាន ឬសម្ភារដល់បេក្ខជន បេក្ខនារី និងកម្មវិធីទាំងមូលដោយមេត្រីភាព។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណទុកជាមុន និងប្រសិទ្ធពរបវរមហាប្រសើរជូនដល់ **ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា** សូមមានសុខភាពល្អ និងប្រកបដោយពុទ្ធពរទាំង៤ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៧
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**


លេខទូរសព្ទទំនាក់ទំនង៖
លោក ហ៊ិន វណ្ណា
០៩៧ ៩០៩ ៧៧៧៧